ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយ

# ស្ដីពី

# ការផ្ដល់អាហារតាមសាលារៀន

# ឆ្នាំ ២០២៤-២០៣៥

រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា

ខែកញ្ញា ឆ្នាំ២០២៤

## មាតិកា


អារម្ភកថា ............................................................................................................ ១

១. សេចក្តីផ្តើម ............................................................................................................ ២

២. ចក្ខុវិស័យ ............................................................................................................ ៥

៣. គោលបំណង ............................................................................................................ ៥

៤. យុទ្ធសាស្ត្រ ............................................................................................................ ៦

- ៤.១. អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ ............................................................ ៦
- ៤.២. លើកកម្ពស់សន្តិសុខសៀ្វងដល់សិស្ស និងគ្រួសារសិស្ស ................................ ៦
- ៤.៣. លើកកម្ពស់ការយល់ដឹងរបស់សហគមន៍ ...................................................... ៦
- ៤.៤. លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ ............................................................ ៧
- ៤.៥. ជំរុញការអភិវឌ្ឍកសិកម្ម និងសេដ្ឋកិច្ចក្នុងសហគមន៍ ......................................... ៧
- ៤.៦. ពង្រឹងអភិបាលកិច្ច ភាពជាដៃគូ និងការសម្របសម្រួលអន្តរវិស័យ ........................ ៧

៥. រៀបចំយន្តការនិងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយ ................................ ៨

- ៥.១. ការបង្កើតយន្តការស្ថាប័ន និងក្របខណ្ឌគតិយុត្ត ................................................ ៨
- ៥.២. ការបណ្តុះបណ្តាលធនធានមនុស្ស និងការគាំទ្រហិរញ្ញវត្ថុ ......................................... ១១
- ៥.៣. ការរៀបចំផែនការសកម្មភាពការអនុវត្តគោលនយោបាយ ......................................... ១២

៦. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ .............................................................. ១២

៧. សេចក្តីសន្និដ្ឋាន ............................................................................................................ ១២

៨. សទ្ទានុក្រម ............................................................................................................ ១៣

## អារម្ភកថា

រាជរដ្ឋាភិបាល បានកំណត់ចក្ខុវិស័យប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកំណត់យកអាទិភាពគន្លឹះចំនួន៥ គឺមនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា។

ការអភិវឌ្ឍមូលធនមនុស្សជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ជំរុញពិពិធកម្ម និងកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងភាពធន់។ មូលធនមនុស្សមានគុណភាពខ្ពស់ និងសុខភាពល្អ ជាទ្រព្យសកម្មជាតិដ៏រឹងមាំសម្រាប់បង្កើនតម្លៃសេដ្ឋកិច្ច លើកកម្ពស់តម្លៃវប្បធម៌ និងបង្កើតគំនិតនវានុវត្តន៍ សំដៅធានាចីរភាពកំណើនរយៈពេលវែង និងជីវភាពនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច។

ក្នុងន័យនេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយ និងកម្មវិធីកែទម្រង់ជាច្រើន ដើម្បីធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម បានផ្តល់ភាពចាំបាច់នៅក្នុងទិដ្ឋភាពសំខាន់ៗលើកម្មវិធីផ្តល់អាហារតាមសាលារៀន ដែលជាផ្នែកមួយនៃប្រព័ន្ធជំនួយសង្គមសម្រាប់ការវិនិយោគរយៈពេលវែង។ កម្មវិធីនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភ ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន។

ដោយមើលឃើញពីភាពចាំបាច់ក្នុងការបន្តពង្រឹង និងពង្រីកសមិទ្ធផលកម្មវិធីផ្តល់អាហារតាមសាលារៀន សំដៅកសាងមូលដ្ឋានគ្រឹះរឹងមាំ រាជរដ្ឋាភិបាលសម្រេចដាក់ចេញគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ឆ្នាំ២០២៤-២០៣៥ នេះ សំដៅធានាការពង្រឹងកិច្ចសហការ និងតួនាទីភារកិច្ចរបស់ក្រសួង-ស្ថាប័នវិស័យឯកជន និងភាគីពាក់ព័ន្ធ ឱ្យមានភាពប្រទាក់ក្រឡា និងបំពេញគ្នាទៅវិញទៅមក។

រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងអស់នឹងចូលរួមគាំទ្រ និងអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ឆ្នាំ២០២៤-២០៣៥ នេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ព្រហស្បតិ៍ ៣ កើត ខែ ភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

## ១. សេចក្តីផ្តើម

ការលុបបំបាត់ភាពអត់ឃ្លាន និងកាត់បន្ថយភាពក្រីក្រនៅតែជាបញ្ហាប្រឈមចម្បងសកល ដែលបានកំណត់ជាអាទិភាពនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។ បញ្ហាទាំងនេះបានផ្តល់កម្មវិបាកអវិជ្ជមានដល់ការអភិវឌ្ឍផ្លូវកាយ ផ្លូវចិត្ត និងផ្លូវអារម្មណ៍របស់មនុស្សគ្រប់រូប ជាពិសេសកុមារមកពីគ្រួសារក្រីក្រ ដែលជាក្រុមងាយរងគ្រោះទៅនឹងភាពមិនប្រាកដប្រជានៃវិបត្តិសកល ដូចជាការរីករាលដាលជំងឺរាតត្បាតសកល គ្រោះធម្មជាតិ និងការប្រែប្រួលអាកាសធាតុជាដើម។

ដើម្បីកសាងសង្គមមួយប្រកបដោយភាពធន់ និងលុបបំបាត់ភាពក្រីក្រ, រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនានា បានធ្វើការរួមគ្នាយ៉ាងសកម្មដើម្បីដាក់ចេញនូវយុទ្ធសាស្រ្ត និងអន្តរាគមន៍ជាច្រើន សំដៅស្វែងរកដំណោះស្រាយនៃបញ្ហាសង្គមដែលកំពុងកើតមានឡើងទាំងនេះ។

ការផ្តល់អាហារតាមសាលារៀន ជាអន្តរាគមន៍សកលដែលមានលក្ខណៈជាយុទ្ធសាស្រ្តក្នុងការរួមចំណែកដល់ការកាត់បន្ថយភាពអត់ឃ្លាន និងលុបបំបាត់ភាពក្រីក្រ។ អន្តរាគមន៍នេះ មានគោលបំណងផ្តល់អាហារូបត្ថម្ភដល់កុមារនៅតាមសាលារៀនឱ្យទទួលបានការអភិវឌ្ឍពេញលេញ និងរួមចំណែកដល់ការអភិវឌ្ឍមូលធនមនុស្សសម្រាប់អនាគត ឆ្ពោះទៅការកសាងសង្គមមួយប្រកបដោយភាពធន់ និងវិបុលភាព។ របាយការណ៍របស់កម្មវិធីស្បៀងអាហារពិភពលោកឆ្នាំ២០២០ បានបង្ហាញថា បច្ចុប្បន្ន ប្រទេសចំនួន៤ ក្នុងចំណោមប្រទេសចំនួន៥ នៅលើពិភពលោក បានអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ដែលក្នុងនោះជាង៩០% នៃថវិកាទ្រទ្រង់កម្មវិធីមានប្រភពមកពីថវិកាជាតិ។ ជាលទ្ធផល, កុមារចំនួនប្រមាណ **៣៨៨លាននាក់** ឬស្មើនឹងជាង **៨០%** នៃចំនួនកុមារសរុបលើពិភពលោក បាន និងកំពុងទទួលអត្ថប្រយោជន៍ពីកម្មវិធីផ្តល់អាហារតាមសាលារៀន ដែលភាគច្រើនលើសលប់នៃកុមារទាំងនោះ កំពុងរស់នៅក្នុងប្រទេសមានចំណូលទាប និងមធ្យមកម្រិតទាប។

ដោយមើលឃើញពីសារៈសំខាន់នៃការផ្តល់អាហារតាមសាលារៀន កម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិបានផ្តួចផ្តើម និងអនុវត្តកម្មវិធីជាច្រើន តាមរយៈកិច្ចសហការជាមួយរដ្ឋាភិបាលជាច្រើននៅលើពិភពលោក ដើម្បីដាក់ចេញគោលនយោបាយពាក់ព័ន្ធ និងគោលការណ៍ណែនាំស្តីពីការផ្តល់អាហារតាមសាលារៀន សំដៅបន្តពង្រីកវិសាលភាពនៃកម្មវិធីឱ្យកាន់តែទូលំទូលាយ។ បន្ថែមលើនេះ, ការផ្តល់អាហារតាមសាលារៀនបានទទួលការគាំទ្រទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុពីធនាគារពិភពលោក ដើម្បីប្រើប្រាស់ជាសំណាញ់សុវត្ថិភាពសង្គមដ៏សំខាន់មួយក្នុងការដោះស្រាយវិបត្តិស្បៀងអាហារសកលលោក។ ជាក់ស្តែង, ប្រទេសចំនួនជាង១០០ប្រទេស នៅលើពិភពលោក បាន និងកំពុងប្រើប្រាស់កម្មវិធីផ្តល់អាហារតាមសាលារៀនជាអន្តរាគមន៍គោលនយោបាយ ដើម្បីដោះស្រាយបញ្ហាសុខភាព អប់រំ សុខុមាលភាព និងបញ្ហាផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងការលូតលាស់របស់មនុស្សទូទៅ និងកុមារ ជាពិសេសអ្នកដែលមានតម្រូវការផ្នែកសុវត្ថិភាព និងសន្តិសុខស្បៀង។

បណ្តាប្រទេសជាច្រើននៅតំបន់អាស៊ី បានអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនជាផ្នែកមួយក្នុងក្របខណ្ឌកម្មវិធីអភិវឌ្ឍជាតិ ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍនានា។ ជាក់ស្តែង, សាធារណរដ្ឋកូរ៉េ (កូរ៉េខាងត្បូង) បានចាប់ផ្តើមអនុវត្តការផ្តល់អាហារថ្ងៃត្រង់នៅតាមសាលារៀនតាំងពីឆ្នាំ១៩៥៣ ក្នុងគោលបំណង

ទាក់ទាញមាតាបិតាឱ្យបញ្ជូនកូនមកសាលារៀន ក្នុងអំឡុងពេលចាប់ផ្តើមអភិវឌ្ឍជាតិ និងគ្របដណ្តប់ចាប់ពីតាមសាលាបឋមសិក្សា មធ្យមសិក្សា និងសាលារៀនអប់រំពិសេស ដើម្បីលើកកម្ពស់សុខភាពរបស់កុមារ ជំរុញការបរិភោគអាហារប្រពៃណី និងកែលម្អរបបអាហារសុខភាពពលរដ្ឋកូរ៉េ។

ប្រទេសថៃបានចាប់ផ្តើមអនុវត្តកម្មវិធីអាហារថ្ងៃត្រង់តាមសាលារៀនជាលើកដំបូងក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ដើម្បីដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភដ៏ស្រួចស្រាវរបស់ពលរដ្ឋថៃ។ ចាប់ពីឆ្នាំ១៩៩៣មក, រាជរដ្ឋាភិបាលថៃបានផ្តល់អាហារថ្ងៃត្រង់រាល់ថ្ងៃសិក្សា។ ការផ្តល់អាហារតាមសាលារៀនមានគោលបំណងលើកកម្ពស់សន្តិសុខស្បៀង កាត់បន្ថយភាពអត់ឃ្លានរយៈពេលខ្លី ដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភ, កែលម្អទម្លាប់បរិភោគអាហារ និងសុខុមាលភាពកុមាររាប់លាននាក់ ជាពិសេសអ្នកដែលរស់នៅក្នុងតំបន់ជួបការលំបាក។

ប្រទេសជប៉ុនសម្រេចបានវិសាលភាពធំជាងគេក្នុងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន។ សាលាបឋមសិក្សា និងមធ្យមសិក្សាទូទាំងប្រទេស បានអនុវត្តកម្មវិធីផ្តល់អាហារថ្ងៃត្រង់ដល់សិស្សផ្អែកតាមបញ្ជីរបបអាហារូបត្ថម្ភដែលរៀបចំដោយអ្នកជំនាញ។ កម្មវិធីនេះ មានគោលបំណងបង្រៀនកុមារពីទម្លាប់ក្នុងការបរិភោគអាហារប្រកបដោយសុខភាពតាំងពីបឋមវ័យ និងជួយឱ្យកុមារយល់ដឹងអំពីសារៈសំខាន់នៃអាហារដែលមានជីវជាតិ ព្រមទាំងផ្តល់ជីវជាតិ និងអាហារូបត្ថម្ភបន្ថែមដល់កុមារ។

នៅប្រទេសឡាវ អាហារថ្ងៃត្រង់តាមសាលារៀន ត្រូវបានផ្តល់ដល់សិស្សនៅថ្នាក់មត្តេយ្យ និងបឋមសិក្សាជាទៀងរាល់ថ្ងៃសិក្សា ដើម្បីជានាឱកាសទទួលបានការអប់រំ និងការបន្តការសិក្សា។ នាឆ្នាំ២០២២ កម្មវិធីផ្តល់អាហារថ្ងៃត្រង់តាមសាលារៀន គ្របដណ្តប់សាលារៀនជាច្រើន រួមចំណែកពង្រឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភរបស់កុមារ និងលើកកម្ពស់កម្មវិធីអនាម័យទឹកស្អាតនៅតាមសាលារៀនក្នុងប្រទេសឡាវ។

ប្រទេសឥណ្ឌូនេស៊ី អនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀននៅឆ្នាំ១៩៩១ តាមរយៈការផ្តល់អាហារសម្រន់។ ការផ្តល់អាហារសម្រន់តាមសាលារៀនបានរួមចំណែកដល់ការលើកកម្ពស់ការអប់រំស្តីពីអាហារូបត្ថម្ភ និងអនាម័យផ្ទាល់ខ្លួននិងកម្មវិធីទម្លាក់ព្រូន។ ចាប់ពីឆ្នាំ២០១៥, ប្រទេសឥណ្ឌូនេស៊ីបានប្តូរពីការផ្តល់អាហារសម្រន់ទៅជាការផ្តល់អាហារពេញលេញវិញ ដែលកម្មវិធីថ្មីនេះអនុវត្តនៅតាមសាលាបឋមសិក្សាគោលដៅយ៉ាងហោចណាស់ចំនួន **៣ដង** ក្នុងមួយសប្តាហ៍។

កស្តុតាងពីការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនពីបណ្តាប្រទេសជាច្រើនលើសកលលោក បានចង្អុលបង្ហាញពីគុណតម្លៃនៃការផ្តល់អាហារតាមសាលារៀន ក្នុងការជួយលើកកម្ពស់កម្រិតអាហារូបត្ថម្ភ, សុខភាព, ការអប់រំ, និងអត្ថប្រយោជន៍សង្គមសេដ្ឋកិច្ចជាច្រើនទៀត។ ការសិក្សាស្រាវជ្រាវរបស់ធនាគារពិភពលោកស្តីពីអាទិភាពនៃការប្រយុទ្ធជំងឺឆ្លង បានបង្ហាញថា ការវិនិយោគលើការអភិវឌ្ឍកុមារនិងមនុស្សវ័យជំទង់ក្នុងអំឡុង ៨០០០ថ្ងៃដំបូង ពិតជាមានសារៈសំខាន់ដល់ការអភិវឌ្ឍមូលធនមនុស្ស។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបានបង្ហាញអំពីបេត់ថ្មីមួយនៃការអភិវឌ្ឍរបស់កុមារ ពោលគឺត្រូវបន្តយកចិត្តទុកដាក់គាំទ្រដល់ការលូតលាស់របស់កុមារក្នុងអំឡុងពេល **៥ឆ្នាំ** ដំបូងរហូតដល់អាយុ១៨ឆ្នាំ ព្រោះជាពេលដែលកុមារភាគច្រើនកំពុងសិក្សា។ ការផ្តល់អាហារតាមសាលារៀនដោយឥតគិតថ្លៃអាចជួយលើកកម្ពស់ដល់ការទទួលបានការអប់រំ និងការសិក្សាប្រកបដោយសមភាពសម្រាប់សិស្សគ្រប់រូប។ ការផ្តល់អាហារតាមសាលារៀនដោយឥតគិតថ្លៃ ជាជម្រើសគោលនយោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការលើកកម្ពស់ការអភិវឌ្ឍនានា ជាពិសេសសម្រាប់ប្រទេសដែលមានអត្រាចុះឈ្មោះចូលរៀនខ្ពស់។

ដោយមើលឃើញអំពីសារៈសំខាន់នៃការផ្តល់អាហារតាមសាលារៀន, ក្រសួងអប់រំ យុវជន និងកីឡា ក្រោមកិច្ចសហការជាមួយកម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ បានចាប់ផ្តើមអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនតាំងពីឆ្នាំ១៩៩៩ នៅសាលាបឋមសិក្សាចំនួន៦៤ ដែលមានអ្នកទទួលផល ៣៧ ៥០០នាក់ និងបន្តពង្រីកជាបន្តបន្ទាប់ដោយប្រើប្រាស់ស្បៀងដែលផ្គត់ផ្គង់ទាំងស្រុងដោយកម្មវិធីស្បៀងអាហារពិភពលោក ក្នុងគោលបំណងផ្តល់លទ្ធភាពដល់កុមារមកពីគ្រួសារក្រីក្របានចូលរៀន។ នៅឆ្នាំ២០១៤ ក្រសួងអប់រំ យុវជន និងកីឡា ក្រោមជំនួយពីកម្មវិធីស្បៀងអាហារពិភពលោក បានចាប់ផ្តើមអនុវត្តសាកល្បងកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ដែលជាគំរូថ្មីមួយក្នុងការផ្តល់អាហារតាមសាលារៀន សំដៅធានាបាននូវអាហារមានសុវត្ថិភាពនិងអាហារូបត្ថម្ភ គាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងអាចអនុវត្តបាន។ កាលពីឆ្នាំ២០១៥, ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក ដើម្បីអភិវឌ្ឍផែនទីបង្ហាញផ្លូវស្តីពីការផ្តល់អាហារតាមសាលារៀន ដែលជាការត្រៀមខ្លួនរបស់រាជរដ្ឋាភិបាលក្នុងការទទួលយកកម្មវិធីផ្តល់អាហារតាមសាលារៀនមកអនុវត្ត និងគ្រប់គ្រងផ្ទាល់។ ក្នុងឆ្នាំសិក្សា ២០១៨-២០១៩, ក្រសួងអប់រំ យុវជន និងកីឡា បានទទួលអនុវត្តសាកល្បងកម្មវិធីនេះនៅខេត្តស្ទឹងត្រែង ដោយប្រើប្រាស់ថវិកាកម្មវិធីស្បៀងអាហារពិភពលោក។ បន្ទាប់មក, កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ត្រូវបានដាក់អនុវត្តជាកម្មវិធីជាតិ កាលពីខែមករា ឆ្នាំ២០២០ សម្រាប់ឆ្នាំសិក្សា ២០១៩-២០២០ ដោយប្រើប្រាស់ថវិកាជាតិ នៅក្នុងស្រុកដែលងាយរងគ្រោះចំនួន១៧ នៃខេត្តចំនួន ៦ រួមមាន សៀមរាប, ព្រះវិហារ, បាត់ដំបង, ស្ទឹងត្រែង, បន្ទាយមានជ័យ, និងកំពង់ចាម ដោយគ្របដណ្តប់សាលារៀនគោលដៅចំនួន **២០៥សាលា** និងផ្តល់អត្ថប្រយោជន៍ដល់សិស្សចំនួន **៥២ ១៣០នាក់**។ គិតត្រឹមឆ្នាំសិក្សា ២០២២-២០២៣, កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ បានអនុវត្តនៅតាមសាលារៀនចំនួន៤២៧ ក្នុងក្រុង/ស្រុកចំនួន២៣ នៃខេត្តគោលដៅចំនួន១០ ដែលសិស្សទទួលអត្ថ-ប្រយោជន៍ពីកម្មវិធីចំនួនរហូតដល់ **១១៣ ៣១៩នាក់** និងបន្តពង្រីកវិសាលភាពតាមសាលាបឋមសិក្សាជាបន្តបន្ទាប់។

ជាក់ស្តែង, ភស្តុតាងនៃការសិក្សាស្រាវជ្រាវនៅកម្ពុជាបានបង្ហាញថា ការផ្តល់អាហារតាមសាលារៀន ជួយបង្កើនការចូលរៀន រក្សាវត្តមានសិក្សា ពង្រឹងការផ្ចង់ស្មារតីក្នុងម៉ោងសិក្សា និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ជាពិសេសសិស្សស្រី។ ការផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ បានរួមចំណែកដល់ការប្រយុទ្ធនឹងការអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភរបស់កុមារ និងអាចជួយធានាឱ្យកុមារទទួលបានអាហារដែលមានសារជាតិចិញ្ចឹមគ្រប់គ្រាន់ និងទៀងទាត់។ របាយការណ៍វាយតម្លៃស្តីពីកម្មវិបាកនៃកម្មវិធីផ្តល់អាហារតាមសាលារៀន បានចង្អុលបង្ហាញពីការចូលរួមចំណែកក្នុងការផ្លាស់ប្តូរជាវិជ្ជមានលើការចុះឈ្មោះចូលរៀនរបស់សិស្សកម្ពុជា ដែលនៅឆ្នាំ២០០១ អត្រាចុះឈ្មោះចូលរៀនមានត្រឹមតែ ៨១% និងកើនឡើងរហូតដល់ ៩៨% នៅឆ្នាំ២០១៩ ជាពិសេសតំបន់ជនបទ និងដាច់ស្រយាល។ បន្ថែមពីនេះ សាលារៀន ក្នុងស្រុកដែលទទួលបានការអន្តរាគមន៍លើកម្មវិធីអាហារតាមសាលារៀន បានបង្ហាញលទ្ធផលជាវិជ្ជមានគួរឱ្យកត់សម្គាល់លើគុណភាពអប់រំ ដូចជាការចុះឈ្មោះចូលរៀនរបស់សិស្សមានការកើនឡើងរហូតដល់៩៩,២% អត្រាបញ្ចប់ការសិក្សាកើនឡើងដល់៨៥,៣% និងការកាត់បន្ថយការបោះបង់ការសិក្សាដល់៤.៥% ខណៈសាលារៀនដែលមិនបានទទួលការអន្តរាគមន៍កម្មវិធីនេះ មានអត្រានៃការចុះឈ្មោះចូលរៀនត្រឹមតែ៩១,២% ការបញ្ចប់ការសិក្សា៨១,៩% ហើយអត្រានៃការបោះបង់ការសិក្សាមានរហូតដល់៤,៨%។

ផ្អែកលើគុណតម្លៃ និងភាពចាំបាច់នៃការផ្តល់អាហារតាមសាលារៀន, រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយ និងក្របខណ្ឌគតិយុត្តពាក់ព័ន្ធជាច្រើន ដែលរួមមានយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ផែនការយុទ្ធសាស្ត្រវិស័យអប់រំ, យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ, ផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព, និងយុទ្ធសាស្ត្ររួមនៃការផ្ទេរ-ទទួលកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ទៅជាកម្មវិធីជាតិ និងការចង្អុលបង្ហាញនៅក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ដើម្បីគាំទ្រដល់ការលើកកម្ពស់សុខភាព អាហារូបត្ថម្ភ សុខុមាលភាព និងការអប់រំរបស់កុមារកម្ពុជា។ គួរកត់សម្គាល់ផងដែរថា ការផ្តល់អាហារតាមសាលារៀនអាចរួមចំណែកដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ រួមមានគោលដៅទី១៖ ការបញ្ចប់ភាពក្រីក្រ, គោលដៅទី២៖ ការបញ្ចប់ភាពអត់ឃ្លាន, គោលដៅទី៣៖ ការលើកកម្ពស់សុខភាព និងសុខុមាលភាព, គោលដៅទី៤៖ ការអប់រំមានគុណភាពប្រកបដោយបរិយាបន្ន និងសមធម៌, គោលដៅទី៥៖ សមភាពយេនឌ័រ, គោលដៅទី៨៖ ការងារសមរម្យនិងកំណើនសេដ្ឋកិច្ច, និងគោលដៅទី១០៖ ការកាត់បន្ថយវិសមភាព។

បើទោះជាមានបទពិសោធក្នុងរយៈពេល២០ឆ្នាំ ក្នុងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀននៅកម្ពុជា, បញ្ហាប្រឈមមួយចំនួននៅតែជាកង្វល់ និងឧបសគ្គដល់ការធានាប្រសិទ្ធភាពកម្មវិធី ដែលរួមមាន ១). ភាពមិនពេញលេញនៃយន្តការកំណត់តួនាទី ទំនួលខុសត្រូវ ការចូលរួម និងការសម្របសម្រួលរវាងអន្តរវិស័យឱ្យបានពេញលេញ ២).កង្វះសង្គតិភាព និងភាពជាប្រព័ន្ធនៃការសម្របសម្រួលក្នុងការផ្តល់កិច្ចអន្តរាគមន៍បន្ថែមលើការអប់រំស្តីពីអាហារូបត្ថម្ភកម្មវិធីទឹកស្អាតនិងអនាម័យ, កម្មវិធីទម្លាក់ព្រូន, កម្មវិធីសួនបន្លែតាមសាលារៀន ឬតាមផ្ទះ ការផ្តល់អាហារបំប៉នមីក្រូសារជាតិ និងការផ្តល់ស្បៀងដល់គ្រួសារសិស្ស ៣).កង្វះយន្តការកម្រិតមូលដ្ឋានក្នុងការកៀរគរធនធាននិងលើកកម្ពស់ភាពជាម្ចាស់ពីសហគមន៍ ៤).កង្វះយន្តការអភិវឌ្ឍសមត្ថភាពជាប្រចាំដល់អ្នកអនុវត្តកម្មវិធីនៅកម្រិតមូលដ្ឋាន ៥). កង្វះយន្តការក្នុងការទាញប្រយោជន៍ពីកម្មវិធីអាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ឱ្យអស់សក្តានុពល និង ៦).កង្វះការកំណត់ស្តង់ដាជាអប្បបរមានៃវិធានអនាម័យនិងសុវត្ថិភាពម្ហូបអាហារ។

## ២. ចក្ខុវិស័យ

គោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន មានចក្ខុវិស័យរួមចំណែកអភិវឌ្ឍមូលធនមនុស្សដោយបំពាក់នូវវិជ្ជាសម្បទា, បំណិនសម្បទា, ចរិយាសម្បទា, និងកាយសម្បទាពេញលេញ សំដៅរួមចំណែកកសាងសង្គមកម្ពុជាឱ្យមានការអភិវឌ្ឍប្រកបដោយវិបុលភាព។

## ៣. គោលបំណង

គោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀនឆ្នាំ២០២៤-២០៣៥ នេះ មានគោលបំណងផ្តល់អាហារប្រកបដោយសុវត្ថិភាព និងអាហារូបត្ថម្ភដល់សិស្ស ដើម្បីជំរុញការលូតលាស់ និងភាពវៃឆ្លាត សំដៅលើកកម្ពស់ផលិតភាពការងារ សមភាពយេនឌ័រ និងបរិយាបន្ន នាពេលអនាគត។

គោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀនមានវិសាលភាពគ្របដណ្តប់ចាប់ពីកម្រិតមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាសាធារណៈ។

## ៤. យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រសំខាន់ៗខាងក្រោមត្រូវបានកំណត់ក្នុងការអនុវត្ត ដើម្បីសម្រេចចក្ខុវិស័យ និងគោលបំណងខាងលើ៖

### ៤.១. អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ

ក្របខណ្ឌច្បាប់ និងយន្តការអនុវត្តគោលនយោបាយ មានសារៈសំខាន់ក្នុងការធានាការសម្របសម្រួល និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីក្នុងដំណាក់កាលកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងការកែទម្រង់រដ្ឋបាលសាធារណៈនៅកម្ពុជា។ ឯកសារច្បាប់ និងក្របខណ្ឌគតិយុត្តទាំងនោះ រួមមានអនុក្រឹត្យ, ប្រកាសអន្តរក្រសួង, សេចក្តីសម្រេចកំណត់ដោយអាជ្ញាធរថ្នាក់ក្រោមជាតិ, ផែនការសកម្មភាពជាតិ, និងយន្តការគាំទ្រនានា។ គោលនយោបាយនេះ ចង្អុលបង្ហាញទិសដៅយ៉ាងច្បាស់សម្រាប់ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ដើម្បីធានាការបន្សុីគ្នារវាងគោលនយោបាយ, ផែនការសកម្មភាព, និងថវិកាសម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាព។ យុទ្ធសាស្ត្រនេះរួមមាន៖

- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងយន្តការនានា ដើម្បីធានាការអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាព បរិយាបន្ន និងសមធម៌ ដោយកំណត់ឱ្យមានកិច្ចសហការ និងភារកិច្ចរបស់ភាគីពាក់ព័ន្ធ
- លើកកម្ពស់ ផ្សព្វផ្សាយ និងជំរុញការអនុវត្តគោលនយោបាយជាតិ ក្របខណ្ឌច្បាប់ យន្តការពាក់ព័ន្ធដែលមានស្រាប់ និងយន្តការដែលនឹងត្រូវបង្កើតថ្មី
- បង្កើតផែនការសកម្មភាពជាតិស្តីពីការផ្តល់អាហារតាមសាលារៀនដោយកំណត់សកម្មភាពជាក់លាក់ ពេល ធនធាន និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ។

### ៤.២. លើកកម្ពស់សន្តិសុខស្បៀងដល់សិស្ស និងគ្រួសារសិស្ស

កម្មវិធីអាហារតាមសាលារៀន ជាសំណាញ់សុវត្ថិភាពសង្គមមួយដែលផ្តល់អត្ថប្រយោជន៍ជាច្រើន ដូចជាការកាត់បន្ថយភាពអត់ឃ្លានរយៈពេលខ្លី, និងលើកកម្ពស់សន្តិសុខស្បៀងដល់សិស្សនិងគ្រួសារសិស្សងាយរងគ្រោះតាមរយៈការផ្តល់អាហារដោយមិនគិតថ្លៃជារៀងរាល់ថ្ងៃសិក្សា។ កម្មវិធីនេះក៏ផ្តល់ឱកាសបង្កើនចំណូលសម្រាប់គ្រួសារដែលងាយរងគ្រោះ រួមបញ្ចូលទាំងចុងភៅ និងកសិករផងដែរ។ ជាក់ស្តែង, ការផ្តល់អាហារតាមសាលារៀនជាប្រចាំជួយសម្រួលដល់ការចំណាយរបស់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្សលើអាហារពេលព្រឹកនៅផ្ទះ និងអាចប្រើប្រាស់ថវិកាទាំងនោះលើការចំណាយដទៃទៀត។ យុទ្ធសាស្ត្រនេះរួមមាន៖

- ពង្រឹងយន្តការកំណត់សាលារៀនគោលដៅសម្រាប់កម្មវិធី
- ធានាការផ្តល់អាហារទាន់ពេលវេលាដល់សិស្សជារៀងរាល់ថ្ងៃសិក្សា
- ធានាកាត់បន្ថយចំណាយរបស់គ្រួសារកុមារមានស្ថានភាពលំបាក។

### ៤.៣. លើកកម្ពស់ការយល់ដឹងរបស់សហគមន៍

កម្មវិធីផ្តល់អាហារតាមសាលារៀន មានសារៈសំខាន់ក្នុងការលើកកម្ពស់ឱកាសទទួលបានសេវាអប់រំប្រកបដោយបរិយាបន្ន និងសមធម៌ ជាពិសេសនៅតំបន់ដែលមានបញ្ហាអសន្តិសុខស្បៀង និងអត្រានៃភាពក្រីក្រនៅមានកម្រិតខ្ពស់។ ការផ្តល់អាហារតាមសាលារៀននេះនឹងជំរុញការយល់ដឹងបន្ថែមដល់សហគមន៍មូលដ្ឋានក្នុងការឱ្យតម្លៃលើមុខងារអាហារសម្រាប់ការអប់រំ សុខភាព និងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈយុទ្ធសាស្ត្រមួយចំនួនរួមមាន៖

- លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់កម្មវិធីផ្តល់អាហារតាមសាលារៀន
- បង្ហាញពីផលជះដែលទទួលបានពីកម្មវិធីផ្តល់អាហារតាមសាលារៀន
- ជំរុញចលនាសហគមន៍ អាជ្ញាធរដែនដី ឱ្យចូលរួម គាំទ្រ និងឧបត្ថម្ភកម្មវិធីផ្តល់អាហារតាមសាលារៀន
- ពង្រីកកម្មវិធីផ្តល់អាហារតាមសាលារៀនតាមលទ្ធភាព និងស្ថានភាពជាក់ស្តែង
- លើកកម្ពស់ការទទួលបានអាហារប្រកបដោយសមធម៌ និងបរិយាបន្ន។

## ៤.៤. លើកកម្ពស់សុខភាពនិងអាហារូបត្ថម្ភ

អាហារតាមសាលារៀន មានតួនាទីយ៉ាងសំខាន់សម្រាប់ទ្រទ្រង់សុខភាព និងអាហារូបត្ថម្ភចំពោះសិស្ស ជាពិសេសអ្នកដែលស្ថិតនៅតំបន់មានបញ្ហាអសន្តិសុខស្បៀងនិងអត្រាភាពក្រីក្រខ្ពស់។ ការផ្តល់អាហារប្រកបដោយសុវត្ថិភាព ជីវជាតិចម្រុះ និងអាហារូបត្ថម្ភគ្រប់គ្រាន់ជារៀងរាល់ថ្ងៃជួយធ្វើឱ្យកុមារទទួលបានរបបអាហារប្រសើរឡើង។ ការផ្តល់អាហារតាមសាលារៀនគួរត្រូវបានផ្សារភ្ជាប់ជាមួយនឹងកម្មវិធីសិក្សាអប់រំសុខភាព និងអាហារូបត្ថម្ភ ដើម្បីពង្រឹងសុខភាព អាហារូបត្ថម្ភ និងអនាម័យ។ យុទ្ធសាស្ត្រនេះរួមមាន៖

- អភិវឌ្ឍ និងអនុវត្តស្តង់ដាអាហារូបត្ថម្ភដោយផ្អែកលើបរិបទជាក់លាក់
- ជំរុញអនុវត្តស្តង់ដាសុវត្ថិភាពម្ហូបអាហារ
- ជំរុញការធ្វើពិពិធកម្មមុខម្ហូបសម្រាប់កម្មវិធី ធានាការផ្សារភ្ជាប់កម្មវិធីផ្តល់អាហារតាមសាលារៀនជាមួយនឹងកម្មវិធីសិក្សាអប់រំសុខភាពនិងអាហារូបត្ថម្ភ
- អភិវឌ្ឍនិងធានាការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងសម្ភារៈចាំបាច់សម្រាប់ដំណើរការកម្មវិធី។

## ៤.៥. ជំរុញការអភិវឌ្ឍកសិកម្មនិងសេដ្ឋកិច្ចក្នុងសហគមន៍

ការប្រើប្រាស់កសិផលក្នុងសហគមន៍សម្រាប់ការផ្គត់ផ្គង់ការផ្តល់អាហារតាមសាលារៀន ជាកត្តាជំរុញការចូលរួមពីអ្នកផ្គត់ផ្គង់ និងកសិករនៅមូលដ្ឋានដែលចូលរួមចំណែកធានាបាននូវនិរន្តរភាពនៃកម្មវិធី និងបង្កើនការផ្សារភ្ជាប់សាលារៀនជាមួយនឹងវិស័យកសិកម្មមូលដ្ឋាន។ កម្មវិធីនេះនឹងលើកកម្ពស់ការប្រើប្រាស់កសិផលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមសហគមន៍ តាមរយៈយុទ្ធសាស្ត្រខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងអ្នកផ្គត់ផ្គង់ឬកសិករក្នុងសហគមន៍អំពីតម្រូវការការផ្គត់ផ្គង់ស្បៀងដល់កម្មវិធីផ្តល់អាហារតាមសាលារៀន
- ចងក្រងសហគមន៍ដើម្បីផ្គត់ផ្គង់កសិផលដល់កម្មវិធីផ្តល់អាហារតាមសាលារៀន
- អភិវឌ្ឍនិងពង្រឹងការអនុវត្តនីតិវិធីការជ្រើសរើសអ្នកផ្គត់ផ្គង់ក្នុងសហគមន៍
- បណ្តុះស្មារតីសិស្ស និងសហគមន៍ឱ្យស្រឡាញ់និងផ្តល់តម្លៃអាហារដែលប្រើប្រាស់កសិផលក្នុងសហគមន៍។

## ៤.៦. ពង្រឹងអភិបាលកិច្ច ភាពជាដៃគូ និងការសម្របសម្រួលអន្តរវិស័យ

ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ទាមទារជាចាំបាច់នូវការសម្របសម្រួលអន្តរវិស័យ និងការបង្កើតឱ្យមានភាពជាដៃគូជាច្រើនស្រទាប់។ ការកសាងនូវប្រព័ន្ធអេកូឡូស៊ីសម្រាប់គាំទ្រការអនុវត្តនឹងជំរុញការចូលរួមចំណែកដល់ការអភិវឌ្ឍនិងការវិនិយោគបន្ថែមរួមគ្នា និងជាប្រចាំតាមរយៈកិច្ចសហប្រតិបត្តិការរួមគ្នា ការផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់ និងការបញ្ចូលនូវការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលជាជម្រើសថ្មីៗ។ កិច្ចការនេះនឹងសម្រេចបាន តាមរយៈយុទ្ធសាស្ត្រខាងក្រោម៖

- ផ្សារភ្ជាប់គោលនយោបាយវិស័យពាក់ព័ន្ធនានាជាមួយនឹងកម្មវិធីផ្តល់អាហារតាមសាលារៀន
- វិភាជថវិកាគាំទ្រកម្មវិធីផ្តល់អាហារតាមសាលារៀនឱ្យបានសមស្រប
- អភិវឌ្ឍធនធានមនុស្សលើផ្នែកបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងនិងអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន
- ពង្រឹងយន្តការសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងនិងអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន
- លើកកម្ពស់ការចូលរួមទៀងទាត់និងសកម្មពីដៃគូអភិវឌ្ឍ វិស័យឯកជន សប្បុរជន និងសហគមន៍ក្នុងការគាំទ្របច្ចេកទេស សម្ភារៈឬហិរញ្ញវត្ថុដល់កម្មវិធីផ្តល់អាហារតាមសាលារៀន។

## ៥. រៀបចំយន្តការនិងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយ

ដើម្បីសម្រេចចក្ខុវិស័យ គោលបំណង និងយុទ្ធសាស្ត្រនៃគោលនយោបាយនេះ, ការរៀបចំយន្តការអនុវត្តគោលនយោបាយ រួមមានៈ

### ៥.១. ការបង្កើតយន្តការស្ថាប័ន និងក្របខណ្ឌគតិយុត្ត

ដើម្បីសម្រេចចក្ខុវិស័យ គោលបំណង និងយុទ្ធសាស្ត្រ គោលនយោបាយនេះ ត្រូវបង្កើតយន្តការស្ថាប័ននិងក្របខណ្ឌគតិយុត្តដូចខាងក្រោមៈ

- ក្រសួងអប់រំ យុវជន និងកីឡា ជាស្ថាប័នដឹកនាំនិងគ្រប់គ្រងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន
- បង្កើតគណៈកម្មការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន
- ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- បង្កើតគណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចលើការអនុវត្តកម្មវិធីថ្នាក់រាជធានី/ខេត្ត ដើម្បីគ្រប់គ្រងនិងសម្របសម្រួលនៅថ្នាក់រាជធានី/ខេត្ត។ គណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចលើការអនុវត្តកម្មវិធីថ្នាក់រាជធានី/ខេត្ត ត្រូវកំណត់ដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី/ខេត្ត
- បង្កើតគណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចលើការអនុវត្តកម្មវិធីថ្នាក់ក្រុង/ស្រុក/ខណ្ឌ ដើម្បីគ្រប់ គ្រងនិងសម្របសម្រួលនៅថ្នាក់ក្រុង/ស្រុក/ខណ្ឌ។ គណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចលើការអនុវត្តកម្មវិធីថ្នាក់ក្រុង/ស្រុក/ខណ្ឌ ត្រូវកំណត់ដោយដីការបស់អភិបាលនៃគណៈអភិបាលក្រុង/ស្រុក/ខណ្ឌ
- បង្កើតគណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចលើការអនុវត្តកម្មវិធីថ្នាក់មូលដ្ឋាន ដើម្បីគ្រប់គ្រងនិងសម្របសម្រួលនៅថ្នាក់ឃុំ/សង្កាត់ និងសាលារៀន។ គណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចលើការអនុវត្តកម្មវិធីថ្នាក់មូលដ្ឋាន ត្រូវកំណត់ដោយដីការបស់ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ និងសាលារៀន។

យន្តការស្ថាប័ន និងក្របខណ្ឌគតិយុត្តទាំងនេះ អាចនឹងមានប្រសិទ្ធភាព លុះត្រាតែមានការបំពេញតួនាទីយ៉ាងពេលលេញពីក្រសួង-ស្ថាប័នសំខាន់ដែលបានកំណត់ និងមានភារកិច្ចតាមការទទួលខុសត្រូវរៀងខ្លួនដូចខាងក្រោមៈ

**ក្រុមប្រឹក្សាជាតិគាំពារសង្គម** មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

១).សម្របសម្រួលកិច្ចសហការរវាងក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនឹងកម្មវិធី

២).ផ្តល់ការតម្រង់ទិសផ្នែកគោលនយោបាយ, យុទ្ធសាស្រ្ត, និងលិខិតបទដ្ឋានគតិយុត្តក្នុងការអនុវត្តកម្មវិធី

៣).ពិនិត្យ តាមដាន និងវាយតម្លៃផ្តល់យោបល់លើវឌ្ឍនភាព

៤).ដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធី និង

៥).រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីជូនរាជរដ្ឋាភិបាល។

**ក្រសួងអប់រំ យុវជន និងកីឡា** មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

១).ដឹកនាំនិងគ្រប់គ្រងការអនុវត្តកម្មវិធី

២).រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រង និងអនុវត្តកម្មវិធី

៣).រៀបចំបង្កើតប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានសម្រាប់គ្រប់គ្រងកម្មវិធី

៤).ពង្រឹងសមត្ថភាពដល់មន្ត្រីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់និងអប់រំផ្សព្វផ្សាយអំពីកម្មវិធី

៥).រៀបចំផែនការសកម្មភាពនិងគម្រោងថវិកាសម្រាប់អនុវត្តកម្មវិធី

៦).រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជូនក្រុមប្រឹក្សាជាតិគាំពារសង្គម

៧).ដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី និង

៨).ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី។

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ** មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

១).សហការផ្តល់ការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

២).សហការជាមួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការជំរុញការដាំបន្លែនៅតាមសាលារៀនដើម្បីបង្កើនអាហារូបត្ថម្ភនៅកម្ពុជា និង

៣).សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធី។

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

១).ពិនិត្យ ផ្តល់យោបល់ និងសម្រេចលើគម្រោងថវិកាសម្រាប់អនុវត្តកម្មវិធី

២).វិភាជថវិកាសម្រាប់ការអនុវត្តកម្មវិធី

៣).ពិនិត្យនិងផ្តល់យោបល់លើរបាយការណ៍ហិរញ្ញវត្ថុ និងសមិទ្ធកម្មរបស់កម្មវិធី និង

៤).សហការ ពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**ក្រសួងមហាផ្ទៃ** មានភារកិច្ចសំខាន់ៗក្នុងការអនុវត្តកម្មវិធី ដូចខាងក្រោម៖

១).រៀបចំនិងបំពេញបន្ថែមលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបំពេញតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការអនុវត្តកម្មវិធី

២).សហការក្នុងការផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិនិងភាគីពាក់ព័ន្ធ

៣).ពង្រឹងយន្តការដែលមានស្រាប់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការពិនិត្យ តាមដាន និងគាំទ្រការអនុវត្តកម្មវិធី និង

៤).សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**ក្រសួងសុខាភិបាល** មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

១).សហការក្នុងការផ្ដល់ការបណ្ដុះបណ្ដាលស្ដីពីរបបអាហារ វិធានអនាម័យ និងព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពអាហារូបត្ថម្ភរបស់កុមារ

២).ត្រួតពិនិត្យ អង្កេត តាមដានអនាម័យសុវត្ថិភាពម្ហូបអាហារនិងគ្រប់គ្រងការពុលចំណីអាហារ

៣).ផ្ដល់ការគាំទ្រផ្នែកបច្ចេកទេសក្នុងការរៀបចំឯកសារពាក់ព័ន្ធនឹងរបបអាហារ វិធានអនាម័យ និងសុវត្ថិភាពម្ហូបអាហារ និង

៤).សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

១).សហការក្នុងការរៀបចំថ្លៃទំនិញ និងចលនាឱ្យមានសហគមន៍កសិករ តាមរយៈការជំរុញឱ្យមានសកម្មភាពផលិតកម្មកសិកម្មប្រកបដោយគុណភាព និងសុវត្ថិភាពនៅតាមសាលារៀនគោលដៅដើម្បីជំរុញការអភិវឌ្ឍកសិកម្មនៅសហគមន៍

២).សហការលើកកម្ពស់គុណភាព សុវត្ថិភាពម្ហូបអាហារ និងអាហារូបត្ថម្ភ

៣).សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការផ្ដល់ការបណ្ដុះបណ្ដាលស្ដីពីចំណេះដឹងផលិតកម្ម កសិកម្មប្រកបដោយសុវត្ថិភាព និង

៤).សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**ក្រសួងផែនការ** មានភារកិច្ចសំខាន់ៗក្នុងការអនុវត្តកម្មវិធី ដូចខាងក្រោម៖

១).ការផ្ដល់ទិន្នន័យតំបន់មានបញ្ហាអសន្តិសុខស្បៀង អត្រាភាពក្រីក្រ និងគ្រួសារក្រីក្រ ដោយប្រើប្រាស់វិធីសាស្ត្រគណនាតំបន់តូចៗ

២).សហការបណ្ដុះបណ្ដាលស្ដីពីសារៈសំខាន់នៃការប្រើប្រាស់អាហារ ការបញ្ចូលមីក្រូសារជាតិនៅក្នុងអាហារ និង

៣).សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

១).សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងនិងស្ថាប័នពាក់ព័ន្ធក្នុងការផ្លាស់ប្ដូរព័ត៌មានអ្នកទទួលផលពីមូលនិធិជាតិជំនួយសង្គម

២).ចូលរួមជំរុញនិងលើកកម្ពស់ជីវភាពរស់នៅរបស់គ្រួសារទទួលផល ពីកម្មវិធីជាតិជំនួយសង្គមតាមរយៈការទទួលបានអត្ថប្រយោជន៍នៃការអនុវត្តកម្មវិធី

៣).សហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍក្នុងការលើកកម្ពស់សកម្មភាពរកចំណូលរបស់គ្រួសារក្រីក្រដែលទទួលផលពីកម្មវិធីជាតិជំនួយសង្គម តាមរយៈការបណ្ដុះបណ្ដាល ការទទួលបានជំនួយឧបត្ថម្ភ និងផលិតកម្មកសិកម្មឬកសិផលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី

៤).សហការនិងផ្សព្វផ្សាយពីអត្ថប្រយោជន៍របស់កម្មវិធីដល់គ្រួសារដែលទទួលផលពីកម្មវិធីជាតិជំនួយសង្គម និង

៥).សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធី។

**ក្រសួងកិច្ចការនារី** មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

១).ចូលរួមលើកកម្ពស់ការយល់ដឹងពីសារៈសំខាន់នៃអាហារូបត្ថម្ភដល់ស្ត្រីនិងកុមារនិងការអប់រំផ្សព្វផ្សាយស្ដីពីការជ្រើសរើសស្បៀងអាហារដែលមានមីក្រូសារជាតិចិញ្ចឹម ដោយផ្សារភ្ជាប់ជាមួយការអនុវត្តកម្មវិធីនៅតាមសាលារៀន

២).ចលនាដល់ការផលិតនិងប្រើប្រាស់កសិផលក្នុងសហគមន៍ដល់ក្រុមគោលដៅជាស្ត្រីតាមរយៈកម្មវិធីសួនបន្លែគ្រួសារនិងការចែកចាយមានតម្លៃសមស្របតាមទីផ្សារ

៣).សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ តាមរយៈគណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ ក្នុងការលើកកម្ពស់ការយល់ដឹង និងការអនុវត្តកម្មវិធី និង

៤).គាំទ្របច្ចេកទេសក្នុងការបញ្ជ្រាបយេនឌ័រក្នុងក្របខណ្ឌពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីនៅតាមគោលដៅ។

**ក្រសួងធម្មការ និងសាសនា** មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

១).សហការជាមួយសាលារៀនក្នុងវត្តអារាម និងសហគមន៍ក្នុងការផ្ដល់អាហារដល់សិស្សក្រីក្រតាមរូបភាពផ្សេងៗ

២).ផ្សព្វផ្សាយការអនុវត្តកម្មវិធី និងការលើកកម្ពស់ពីសុវត្ថិភាពអាហារូបត្ថម្ភ តាមរយៈបព្វជិតសាសនានៅតាមសហគមន៍និងសាលារៀនក្នុងវត្ត

៣).កៀរគរការចូលរួមរបស់សហគមន៍ក្នុងការអនុវត្តការផ្ដល់អាហារតាមសាលារៀនតាមរយៈបព្វជិតសាសនា និងគណៈកម្មការអារាមសាសនា ដែលដើរតួជាអ្នកសង្គមកិច្ចសម្ព័ន្ធ និង

៤).សហការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីអាហារតាមសាលារៀន។

**រដ្ឋបាលក្រុង ស្រុក** មានភារកិច្ចក្នុងការអនុវត្តកម្មវិធី ដូចជា៖

១).ប្រមូលនិងបូកសរុបសំណើសុំថវិកាសម្រាប់ការអនុវត្តកម្មវិធីផ្ដល់អាហារតាមសាលារៀន

២).កៀរគរធនធាន ថវិកា និងសម្ភារៈពីអ្នកពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធី និង

៣).ពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**ក្រសួង និងអាជ្ញាធរពាក់ព័ន្ធនានា** ត្រូវផ្ដល់ការគាំទ្រដល់ការអនុវត្តកម្មវិធីផ្ដល់អាហារតាមសាលារៀនតាមគ្រប់រូបភាព ឬមធ្យោបាយផ្សេងៗដែលមានភាពទន់ភ្លន់និងតាមលទ្ធភាព។

## ៥.២. ការបណ្ដុះបណ្ដាលធនធានមនុស្ស និងការគាំទ្រហិរញ្ញវត្ថុ

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយស្ដីពីការផ្ដល់អាហារតាមសាលារៀន ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់បណ្ដុះបណ្ដាលធនធានមនុស្សគ្រប់កម្រិតឱ្យមានសមត្ថភាពលើជំនាញគ្រប់គ្រង រដ្ឋបាល ហិរញ្ញវត្ថុ ផែនការ និងបច្ចេកទេសពាក់ព័ន្ធនឹងកម្មវិធីផ្ដល់អាហារតាមសាលារៀន។

បន្ថែមលើនេះ, រាល់ចំណាយលើការអនុវត្តកម្មវិធី ត្រូវផ្ដល់ហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាពីប្រភពស្របច្បាប់ផ្សេងទៀត។

### ៥.៣. ការរៀបចំផែនការសកម្មភាពការអនុវត្តគោលនយោបាយ

ដើម្បីគាំទ្រ ប្រមូលធនធាន និងធានាប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិក្នុងការអនុវត្តគោលនយោបាយនេះ ផែនការសកម្មភាពស្តីពីការផ្តល់អាហារតាមសាលារៀនរយៈពេលខ្លី មធ្យម និងវែង នឹងត្រូវបង្កើតឡើងដោយផ្អែកលើភស្តុតាង និងការពិគ្រោះយោបល់ពីគ្រប់ភាគីពាក់ព័ន្ធឱ្យបានទូលំទូលាយ។ ផែនការសកម្មភាពនេះត្រូវឆ្លុះបញ្ចាំងពីចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សុខភាពនិងអាហារូបត្ថម្ភ ការអប់រំ ការអភិវឌ្ឍកសិកម្ម និងសេដ្ឋកិច្ចនៅក្នុងសហគមន៍ និងត្រូវឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ព្រមទាំងត្រូវអនុវត្តនៅក្នុងក្របខណ្ឌកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ។

## ៦. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

ដើម្បីអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ឆ្នាំ២០២៤-២០៣៥ ឱ្យមានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ ចាំបាច់ត្រូវមានប្រព័ន្ធតាមដាន ពិនិត្យ និងវាយតម្លៃ និងសំណើកែលម្អការអនុវត្តដោយផ្តោតលើ៖

- ធានាគណនេយ្យភាពសមិទ្ធកម្មដោយផ្តោតលើការប្រើប្រព័ន្ធបច្ចេកវិទ្យាទំនើប
- សូចនាករសមិទ្ធកម្មដែលបានកំណត់នៅក្នុងក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃ នៃគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀនឆ្នាំ២០២៤-២០៣៥
- អនុលោមភាពស្តង់ដាអាហារូបត្ថម្ភ និងសុវត្ថិភាពម្ហូបអាហារ
- របាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀនតាមការកំណត់។

## ៧. សេចក្តីសន្និដ្ឋាន

គោលនយោបាយនេះឆ្លុះបញ្ចាំងពីចក្ខុវិស័យ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការអប់រំ, សុខភាពនិងសុខុមាលភាព, សេដ្ឋកិច្ច, និងកសិកម្មនៅកម្ពុជា ដើម្បីរួមចំណែកដល់ការឈានទៅសម្រេចមហិច្ឆតាប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ដើម្បីអនុវត្តគោលនយោបាយនេះឱ្យមានប្រសិទ្ធភាព ទាមទារឱ្យមានការគាំទ្រនិងកិច្ចសហការពេញលេញទាំងផ្នែកស្មារតី, សម្ភារៈ, និងគណនេយ្យភាពសមិទ្ធកម្ម។ រាជរដ្ឋាភិបាលសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា ក្រសួង-ស្ថាប័នពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ ព្រមទាំងភាគីពាក់ព័ន្ធ នឹងសហការ ជំរុញ ផ្សព្វផ្សាយ គាំទ្រ និងអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀនឆ្នាំ២០២៤-២០៣៥ ឱ្យទទួលបានជោគជ័យនិងមានប្រសិទ្ធភាពខ្ពស់។

## ៨. សទ្ទានុក្រម

- **កម្មវិធីផ្តល់អាហារតាមសាលារៀន៖** សំដៅដល់កម្មវិធីដែលផ្តល់អាហារដល់កុមារនៅតាមសាលារៀនដើម្បីលុបបំបាត់សេចក្តីស្រេកឃ្លាន គាំទ្រការអប់រំ និងលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភកុមារ។ កម្មវិធីនេះ អាចធ្វើឡើងក្នុងរូបភាពផ្តល់អាហារសម្រាប់កុមារបរិភោគនៅក្នុងសាលារៀន ឬការផ្តល់ស្បៀងដល់គ្រួសាររបស់កុមារនៅពេលពួកគេមករៀនទៀងទាត់។
- **កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍៖** សំដៅដល់ការផ្តល់អាហារស្រស់ដែលមានប្រភពផលិត និងទិញនៅក្នុងសហគមន៍ ឬប្រទេស ដោយផ្តោតលើសុវត្ថិភាពម្ហូបអាហារ ភាពចម្រុះនៃអាហារ និងអាហារូបត្ថម្ភដល់កុមារនៅតាមសាលារៀន ដែលការផ្តល់ឱ្យនេះអាចធ្វើឡើងតាមរូបភាពជាការផ្តល់អាហារពេលព្រឹក ឬអាហារពេលថ្ងៃ។
- **កសិផលក្នុងសហគមន៍៖** សំដៅដល់ផលិតផល មានដូចជា អង្ករ ត្រី សាច់ ស៊ុត ទឹកដោះសត្វ បន្លែ ផ្លែឈើ គ្រាប់ធញ្ញជាតិ ចំណីអាហារដែលបញ្ចូលមីក្រូសារជាតិជាដើមក្នុងសហគមន៍ដែលមានប្រភពពីផលិតកម្មដំបូង និងអាចរកទិញបានសម្រាប់ផ្គត់ផ្គង់នៅតាមសាលារៀនសាធារណៈ។
- **ភាពចម្រុះនៃអាហារ៖** សំដៅដល់ភាពសម្បូរបែបនៃមុខម្ហូបឬក្រុមមុខម្ហូបដែលបរិភោគ។
- **មូលធនមនុស្ស៖** សំដៅដល់ការរួមបញ្ចូលគ្នានៃបំណិន ចំណេះដឹង ជំនាញការ និងសុខភាពដែលអាចឱ្យក្លាយជាពលរដ្ឋមានសមត្ថភាពក្នុងសង្គម។ ការគាំទ្រកុមារដោយផ្តល់ការអប់រំនិងអាហារដែលមានសុខភាពល្អពិតជាសំខាន់សម្រាប់កសាងមូលធនមនុស្ស។
- **សាលារៀនគោលដៅ៖** សំដៅដល់សាលារៀនសាធារណៈដែលត្រូវបានជ្រើសរើសនិងកំណត់សម្រាប់ការអនុវត្តកម្មវិធី។
- **សុវត្ថិភាពម្ហូបអាហារ៖** សំដៅដល់ការអនុវត្តដំណើរការធានាថា ម្ហូបអាហារមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់នៅពេលដែលត្រូវបានយកទៅធ្វើការរៀបចំ ឬបរិភោគស្របតាមកម្មវត្ថុប្រើប្រាស់របស់ម្ហូបអាហារនោះ។
- **អាហារសុខភាព៖** សំដៅដល់អាហារដែលជួយការពារនូវកង្វះអាហារូបត្ថម្ភរួមមាន កង្វះមីក្រូសារជាតិ និងប្រឆាំងជំងឺផ្សេងៗដូចជា ជំងឺទឹកនោមផ្អែម ជំងឺបេះដូង ជំងឺដាច់សរសៃឈាម និងជំងឺមហារីកជាដើម។
- **អាហារូបត្ថម្ភ៖** សំដៅដល់អាហារដែលមានសុខភាពនិងតុល្យភាព។ អាហារនិងភេសជ្ជៈផ្តល់នូវថាមពលនិងសារជាតិចិញ្ចឹមចាំបាច់សម្រាប់សុខភាព។ ការបរិភោគអាហារដែលមានសភាពសម្បូរបែបគឺល្អបំផុតសម្រាប់សុខភាព។